ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមព្រហ្មទណ្ឌ

លេខ ៨ "ច"ត្រ.២

ចុះថ្ងៃទី៦ ខែមករា ឆ្នាំ២០២១

-សំណុំរឿងព្រហ្មទណ្ឌលេខ ៣៦៨៨

ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២០

-សំណុំរឿងស៊ើបសួរលេខ ២៤៥១

ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២០

-សំណុំរឿងជំនុំជម្រះលេខ ៥៥៦៣

ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២០

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោង ៨ :៣០នាទីព្រឹក នៅសាលសវនាការទី៤ ដោយមានសមាសភាព៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

-លោកចៅក្រម [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ

-លោកស្រីចៅក្រម [redacted] ជាចៅក្រមប្រឹក្សា

-លោកស្រីចៅក្រម [redacted] ជាចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

-លោក [redacted] ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៣៦៨៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២០ ដែលមានជនជាប់ចោទឈ្មោះ [redacted] **ធារី** ភេទស្រី អាយុ ៥៣ឆ្នាំ ជនជាតិខ្មែរ មុខរបរលក់បន្លែ ទីកន្លែងកំណើតនៅ [redacted] ខេត្តស្វាយរៀង អាសយដ្ឋានបច្ចុប្បន្ននៅផ្ទះលេខ [redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ប៊ុន(ស)ម្តាយឈ្មោះ [redacted] នូ(ស) ប្តីឈ្មោះ [redacted] ស៊ីម៉ា មានកូន ១នាក់ ទោសពីមុន គ្មាន។

-ឃាត់ខ្លួនថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២០/ឃុំខ្លួនថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២០ (PJ)។

ជាប់ចោទពីបទ: **ជួញដូរ(ប្រព្រឹត្តច្រើនដង)និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចផ្ទះលេខ១៣៣ ក្រុម១៤ ផ្លូវលំ ភូមិផ្សារតូច សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៩ រហូតដល់ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ (ក៥ច១)និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-មានលោកមេធាវី [redacted] និងលោកស្រីមេធាវី [redacted] (**ក្រុមមេធាវី ឌី ស៊ី**)អាសយដ្ឋានផ្ទះលេខ៣០៩ ផ្លូវលេខ១៦៣ សង្កាត់ទួលទំពូង២ ខណ្ឌចំការមន រាជធានីភ្នំពេញ ការពារសិទ្ធិឲ្យជនជាប់ចោទ។

### អង្គហេតុនៃរឿងមានដូចតទៅ

-នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២០ វេលាម៉ោង ១៥ :៣០នាទីកម្លាំងកងរាជអាវុធហត្ថខណ្ឌឫស្សីកែវបានចុះបង្ក្រាបបទល្មើសជាក់ស្តែងនៅចំណុចផ្ទះលេខ១៣៣ ក្រុម១៤ ផ្លូវលំ ភូមិផ្សារតូច សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឃាត់ខ្លួនជនសង្ស័យឈ្មោះ [redacted] **ធារី** ភេទស្រី ដកហូតបានក្រាមម្សៅថ្លាចំនួន ១២កញ្ចប់ ,ជញ្ជីងអេឡិចត្រូនិចចំនួន ១ និងបន្ទាប់ពីការសាកសួរជនសង្ស័យឈ្មោះ [redacted] **ធារី** បានសារភាពថា បានរកស៊ីលក់គ្រឿងញៀនរយៈពេល



Scanned with CamScanner

១ឆ្នាំហើយ ក្រាមម៉្សៅថ្លាចំនួន ១២កញ្ចប់ ,ជញ្ជីងអេឡិចត្រូនិចចំនួន១។ ខ្លួនទិញគ្រឿងញៀនពីឈ្មោះ [redacted] ភេទស្រី ម្ដង កន្លះខាំ ក្នុងតម្លៃ ៨៥០$ និងទិញពីឈ្មោះ [redacted] ភេទស្រី រស់នៅអាសយដ្ឋានមិនចាំ សង្កាត់ទួលសង្កែ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ទិញម្ដងកន្លះជ្រុង តម្លៃ ៩០ម៉ឺនរៀល សមត្ថកិច្ចក៏បានកសាងសំណុំរឿងបញ្ជូនមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញចាត់ការតាមច្បាប់។

-បានឃើញ ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៦១៣២ "ទ"ដ.ឃ.ដ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ របាយការណ៍សរុបលេខ ១៧៩/២០ រ.ប.ក ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២០ របស់ការិយាល័យប្រឆាំងគ្រឿងញៀននៃកងរាជអាវុធហត្ថរាជធានីភ្នំពេញ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ២៦៥៨ អ.យ.ធ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៤៨៨២ អ.យ.ធ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៦២៦៦"ទ"ដ.ដ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] **ឆាទី** បានឆ្លើយថា: ខ្ញុំចេះប្រើប្រាស់គ្រឿងញៀន ៦ឆ្នាំហើយ។ ខ្ញុំលក់គ្រឿងញៀនរយៈពេល ១ឆ្នាំហើយ។ ជញ្ជីងថ្លឹងគ្រឿងញៀនមិនមែនជារបស់ខ្ញុំទេ ជារបស់ឈ្មោះ អឿន យកមកផ្ញើខ្ញុំ ,ចម្លើយនៅសមត្ថកិច្ចខ្ញុំទទួលស្គាល់ ,ខ្ញុំបានទិញគ្រឿងញៀនពីឈ្មោះ **អឿន** ចំនួន ១០ដង យកទៅលក់បន្តពិតមែន ទិញតម្លៃ ៨៥០$ និងទិញពីឈ្មោះ **ស្រីប** ម្ដងកន្លះជ្រុង តម្លៃ ៣០០.០០០(សាមសិបម៉ឺន)រៀល គ្រឿងញៀនខ្ញុំទិញមកម្ដង លក់រយៈពេល ១០ថ្ងៃ ហើយ ១ថ្ងៃលក់ចំណេញ ៣០.០០០(បីម៉ឺន)រៀល ទៅ ៤០.០០០(បួនម៉ឺន)រៀល ,គ្រឿងញៀនជួនកាលគេយកមកឱ្យ ជួនកាលទៅយកដោយខ្លួនឯង។ ខ្ញុំជាអ្នកលក់បន្លែ និងរស់នៅពីនាក់ប្ដី ចំណូលប្ដីរកបាន ១ខែ ៤០០.០០០(សែសិបម៉ឺន)រៀល។ សមត្ថកិច្ចបានមកឃាត់ខ្លួនខ្ញុំនៅផ្ទះដកហូតគ្រឿងញៀន ,ជញ្ជីងសម្រាប់ថ្លឹងគ្រឿងញៀន និងទូរស័ព្ទ។

## សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ

-ក្រោយពេលស្ដាប់ការសួរដេញដោល ជនជាប់ចោទបានឆ្លើយសារភាពមានភាពស៊ីសង្វាក់និងអង្គហេតុ ជនជាប់ចោទបានរកស៊ីទិញលក់គ្រឿងញៀនច្រើនដង យកទៅលក់ចែកចាយបន្តដើម្បីទទួលបានប្រាក់ចំណេញ តំណាងអយ្យការនៅតែរក្សាបទចោទតាមដីការសន្និដ្ឋានស្ថាពរ និងសុំឱ្យតុលាការផ្ដន្ទាទោសជនជាប់ចោទតាមច្បាប់។

## សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

-តាមអង្គហេតុ និងចម្លើយកូនក្ដីខ្លួនក្នុងអង្គសវនាការ កូនក្ដីខ្លួនបានឆ្លើយសារភាពនូវទោសកំហុស មិនបានឆ្លើយដោះសារគេចវេសឡើយ កូនក្ដីខ្លួនជាជនចាស់ជរា មានស្មារតីដឹងនូវកំហុស និងបានកែប្រែខ្លួនចូលក្នុងសង្គមវិញ នាងខ្ញុំសុំឱ្យតុលាការពិចារណាបន្ធូរបន្ថយទោសដល់កូនក្ដីរបស់ខ្លួនផង។

## សំដីចុងក្រោយរបស់ជនជាប់ចោទ

-ជនជាប់ចោទឈ្មោះ [redacted] **ឆាទី** បានឆ្លើយថា: សុំឱ្យតុលាការបន្ធូបន្ថយទោសផង។



Scanned with CamScanner

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់យោបល់ចៅក្រមប្រឹក្សា

-ក្រោយពីបានស្តាប់ជនជាប់ចោទនិយាយសំដីចុងក្រោយ

-ក្រោយពីបានពិនិត្យលើឯកសារ ភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## **សំអាងហេតុ**

១-តាមរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ និងភស្តុតាងទាំងអស់ដែលស្វែងរកដោយចៅក្រមស៊ើបសួរ ពុំមានភាពផ្ទុយគ្នាទេ។ យោងតាមមាត្រា១១០ និងមាត្រា១១៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ អាចឱ្យតុលាការជឿបានថា: នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២០ វេលាម៉ោង ១៥ :៣០នាទីកម្លាំងកងរាជអាវុធហត្ថខណ្ឌឫស្សីកែវបានចុះបង្ក្រាបបទល្មើសជាក់ស្តែងនៅចំណុចផ្ទះលេខ១៣៣ ក្រុម១៤ ផ្លូវលំ ភូមិផ្សារតូច សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឃាត់ខ្លួនជនសង្ស័យឈ្មោះ [redacted]**ធាវី** ភេទស្រី ដកហូតបានក្រាមម៉្សៅថ្លាចំនួន ១២កញ្ចប់ ,ជញ្ជីងអេឡិចត្រូនិចចំនួន ១ និងបន្ទាប់ពីការសាកសួរជនសង្ស័យឈ្មោះ[redacted]**ធាវី** បានសារភាពថា បានរកស៊ីលក់គ្រឿងញៀនរយៈពេល ១ឆ្នាំហើយ ក្រាមម៉្សៅថ្លាចំនួន ១២កញ្ចប់ ,ជញ្ជីងអេឡិចត្រូនិចចំនួន១។ ខ្លួនទិញគ្រឿងញៀនពីឈ្មោះ **អឿន** ភេទស្រី ម្តងកន្លះខាំ ក្នុងតម្លៃ ៨៥០$ និងទិញពីឈ្មោះ **ច្រឹប** ភេទស្រី រស់នៅអាសយដ្ឋានមិនចាំ សង្កាត់ទួលសង្កែ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ទិញម្តងកន្លះជ្រុង តម្លៃ ៩០ម៉ឺនរៀល សមត្ថកិច្ចក៏បានកសាងសំណុំរឿងបញ្ជូនមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញចាត់ការតាមច្បាប់។

២-តាមចម្លើជនជាប់ចោទឈ្មោះ [redacted]**ធាទី** បានឆ្លើយសារភាពថា: ខ្លួនចេះប្រើប្រាស់គ្រឿងញៀន ៦ឆ្នាំ និងលក់គ្រឿងញៀនរយៈពេល ១ឆ្នាំហើយ។ ជញ្ជីងថ្លឹងគ្រឿងញៀនមិនមែនជារបស់ខ្លួនទេ ជារបស់ឈ្មោះ **អឿន** យកមកផ្ញើ ,ចម្លើយនៅសមត្ថកិច្ចខ្លួនទទួលស្គាល់ ,ខ្លួនបានទិញគ្រឿងញៀនពីឈ្មោះ **អឿន** ចំនួន ១០ដង យកទៅលក់បន្តពិតមែនទិញតម្លៃ ៨៥០$ និងទិញពីឈ្មោះ **ច្រឹប** ម្តងកន្លះជ្រុង តម្លៃ ៣០០.០០០(សាមសិបម៉ឺន)រៀល គ្រឿងញៀនទិញមកម្តងលក់រយៈពេល ១០ថ្ងៃ ហើយ ១ថ្ងៃលក់ចំណេញ ៣០.០០០(បីម៉ឺន)រៀល ទៅ ៤០.០០០(បួនម៉ឺន)រៀល ,គ្រឿងញៀនជួនកាលគេយកមកឱ្យលក់ ជួនកាលទៅយកដោយខ្លួនឯង។ សមត្ថកិច្ចបានមកឃាត់ខ្លួននៅផ្ទះ ដកហូតគ្រឿងញៀន ,ជញ្ជីងសម្រាប់ថ្លឹងគ្រឿងញៀន និងទូរស័ព្ទ។

ភស្តុតាងទាំងអស់ខាងលើនេះអាចឱ្យតុលាការពិចារណាបានតាមមាត្រា៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៣-ជនជាប់ចោទឈ្មោះ [redacted]**ធាទី** ភេទស្រី អាយុ ៥៣ឆ្នាំ ជានីតិជន មានកាយសម្បទាគ្រប់គ្រាន់ ពុំមានភស្តុតាងណាមួយបញ្ជាក់ថា មានបញ្ហាខាងស្មារតីឡើយ ដូច្នេះជនជាប់ចោទដែលមានសមត្ថភាពទទួលខុសត្រូវខាងព្រហ្មទណ្ឌ ពោលគឺពិតជាមានស្មារតីយល់ដឹងពីផលវិបាកដែលកើតចេញពីការប្រព្រឹត្តរបស់ខ្លួនស្របតាមមាត្រា៣៨ នៃក្រមព្រហ្មទណ្ឌ។



Scanned with CamScanner

៤-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] **ឆាទី** ភេទស្រី ដែលបានប្រើប្រាស់គ្រឿងញៀន និងទិញគ្រឿងញៀនយកទៅលក់បន្តឱ្យអ្នកដទៃជាច្រើនដងក្នុងគោលបំណងទទួលបានប្រាក់ចំណេញ គឺជាអំពើ **ជួញដូរនិងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** និងបានធ្វើឱ្យប៉ះពាល់ដល់របៀបរៀបរយ សណ្តាប់ធ្នាប់សាធារណៈ សន្តិសុខសង្គម ប៉ះពាល់ធ្ងន់ធ្ងរដល់សុខភាពខ្លួនឯង ដល់សុខភាពអ្នកដទៃ ដែលក្រមព្រហ្មទណ្ឌត្រង់មាត្រា២ និងមាត្រា៣ បានហាមឃាត់ដាច់ខាត និងត្រូវផ្តន្ទាទោស។

៥-តាមកំណត់ហេតុទទួលវត្ថុចាប់យកលេខ ១៧១១ វវត ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២០ របស់សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ វត្ថុចាប់យករួមមាន៖

-ក្រាមពណ៌សថ្លាចំនួន ១២(ដប់ពីរ)កញ្ចប់ ទម្ងន់ ១៦៩,១៩ក្រាម(មួយរយហុកសិបប្រាំបួនកណ្តកសញ្ញាដប់ប្រាំបួន) ,-ជញ្ជីងសម្រាប់ថ្លឹងគ្រឿងញៀនម៉ាក POCKET ពណ៌ខ្មៅ ចំនួន ១គ្រឿង និងថង់សម្រាប់ច្រកគ្រឿងញៀនមួយចំនួន។ គប្បីរឹបអូសតាមបញ្ញត្តិមាត្រា៦២ ,មាត្រា៦៣ នៃក្រមព្រហ្មទណ្ឌ និងបញ្ញត្តិមាត្រា៩៣ ,មាត្រា៩៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-កាបូបដៃចំនួន ២(ពណ៌ក្រហមចំនួន១ ,ពណ៌សលាយក្រហមចំនួន១) និងទូរស័ព្ទដៃម៉ាកណូគាពណ៌ខ្មៅ(មិនដំណើការ)ចំនួន១។ គប្បីប្រគល់ឱ្យម្ចាស់ដើមវិញតាមបញ្ញត្តិមាត្រា៣៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៦-តាមលទ្ធផលកោសលវិច័យគ្រឿងញៀនលេខ ២៦៦១១/២០ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២០ របស់មន្ទីរពិសោធន៍ នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនមានលេខសម្គាល់ឯកសារមន្ទីរពិសោធន៍ PPC ២៤៣៩៤ លើសំណាកជាប្រភេទក្រាមម្សៅថ្លា ពណ៌ស ជាលទ្ធផល **វិជ្ជមាន** ,វត្ថុមានសារធាតុញៀនឈ្មោះមេតំហ្វេតាមីន(Methamphetamine)(ហៅក្រៅអាយឬម៉ាទឹកកក)ដែលមានកម្រិតភាពសុទ្ធ ៧៩,៣៦% (ចិតសិបប្រាំបួនកណ្តកសញ្ញាសាមសិបប្រាំមួយភាគរយ)នៃទម្ងន់សរុបវាស្ថិតក្នុងតារាងទី២ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀន ដូចមានចែងក្នុងតារាងឧបសម្ព័ន្ធច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។ ដូចនេះយើងអាចគណនាភាពសុទ្ធសរុបទាំងអស់មានទម្ងន់ស្មើ $\frac{៧៩.៣៦ \times ១៦៩.១៩}{១០០} = ១៣៤.២៦៨g$ វាមានធាតុផ្សំគ្រប់គ្រាន់តាមមាត្រា៤០ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៧-មានពិរុទ្ធភាពគ្រប់គ្រាន់ដើម្បីដាក់បន្ទុកលើឈ្មោះ [redacted] **ឆាទី** ភេទស្រី អាយុ ៥៣ឆ្នាំ ពីបទ: **ជួញដូរ (ប្រព្រឹត្តច្រើនដង)និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅ ចំណុចផ្ទះលេខ១៣៣ ក្រុម១៤ ផ្លូវលំ ភូមិផ្សារតូច សង្កាត់ទួលសង្កែ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៩ រហូតដល់ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០(ក៥ច១) និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

## ហេតុដូច្នេះសម្រេច

ក-ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] **ឆាទី** ភេទស្រី អាយុ ៥៣ឆ្នាំ(សាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ១០(ដប់)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ២០.០០០.០០០(ម្ភៃលាន)រៀល ពីបទ: **ជួញដូរ(ប្រព្រឹត្តច្រើនដង)និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចផ្ទះលេខ១៣៣ ក្រុម១៤ ផ្លូវលំ ភូមិផ្សារតូច



Scanned with CamScanner

សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៩ រហូតដល់ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា៤០(ក៥ច១) និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ខ-វត្ថុចាប់យករួមមាន៖

១-គ្រឿងញៀនប្រភេទក្រាមម្សៅឈ្មោះមេតំហ្វេតាមីន(Methamphetamine)(ហៅក្រៅអាយ ឬម៉ាទឹកកក)ទម្ងន់ ១៦៩,១៩ក្រាម ដែលមានកម្រិតភាពសុទ្ធ ៧៩,៣៦%នៃទម្ងន់សរុប ,-ជញ្ជីងសម្រាប់ថ្លឹងគ្រឿងញៀនម៉ាក POCKET ពណ៌ខ្មៅ ចំនួន ១គ្រឿង និងថង់សម្រាប់ច្រកគ្រឿងញៀនមួយចំនួន រឹបអូស។

២-កាបូបដៃចំនួន ២(ពណ៌ក្រហមចំនួន១ ,ពណ៌សណាយក្រហមចំនួន១) និងទូរស័ព្ទដៃម៉ាកណូគាពណ៌ខ្មៅ(មិនដំណើការ)ចំនួន១ ប្រគល់ឱ្យម្ចាស់ដើមវិញ។

-សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០ និងប្រកាសជាសាធារណៈនៅថ្ងៃទី៦ ខែមករា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ធារី។

-ទុកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា និងត្រា |

[redacted]

---

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម។

ថ្ងៃពុធ ៨រោច ខែបុស្ស ឆ្នាំជូត ទោស័ក ពុទ្ធសករាជ២៥៦៤

រាជធានីភ្នំពេញ ,ថ្ងៃទី៦ ខែមករា ឆ្នាំ២០២១

**ក្រឡាបញ្ជី**

[redacted]